សលាកប័ត្រព័ត៌មាន៖ កម្រងអត្ថបទសិទ្ធិជាមូលដ្ឋាន (សេរីភាពខាងជំនឿនៅកម្ពុជា)

សិទ្ធិមូលដ្ឋាន៖ សេរីភាពខាងជំនឿ

រូបភាពរួម៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (“រដ្ឋធម្មនុញ្ញ”) ក៏ដូចជាច្បាប់អន្តរជាតិនានាផងដែរ សុទ្ធតែបានការពារសេរីភាពខាងជំនឿ។ ទោះបីហាក់ដូចជាប្រញាប់ប្រញាល់ពេកដើម្បីប្រកាសថាព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) មានសេរីភាពខាងជំនឿយ៉ាងពេញលេញ គេសង្កេតឃើញមានការរីកចម្រើនយ៉ាងធំធេងចាប់តាំងពីការដួលរលំរបបខ្មែរក្រហម និងរបបកុម្មុយនីស្ត ដោយនាពេលបច្ចុប្បន្ននេះក្រុមជំនឿសាសនាភាគតិចជាទូទៅប្រឈមមុខនឹងការរើសអើងតិចជាងមុន ហើយនេះបញ្ហាក់ពីមូលហេតុចំពោះកម្រិតត្រឹមត្រូវនៃសុទិដ្ឋិនិយមនៅក្នុងសេរីភាពខាងជំនឿ។ ទោះជាយ៉ាងណាក៏ដោយ សិទ្ធិសេរីភាពខាងជំនឿ គឺត្រូវតែមានលក្ខណៈដាច់ខាត ហើយមិនគួរត្រូវបានគេរឹតត្បឹតឡើយ មិនថានៅក្នុងកាលៈទេសៈណាក៏ដោយ និយាយរួមបើទោះជាគោលបំណងនៃការរឹតត្បឹតគឺសំដៅរឹតត្បឹតសិទ្ធិសេរីភាពឯទៀតដូចជាសិទ្ធិពលរដ្ឋ ឬសិទ្ធិនយោបាយ ជាជាងការរឹតត្បឹតដោយឈរលើមូលដ្ឋានជំនឿសុទ្ធសាធក៏ដោយ។

សេចក្តីផ្តើម

មួយថ្ងៃក្រោយពីកាសែត ឌឺ ភ្នំពេញប៉ុស្តិ៍ បានរាយការណ៍អំពីការបង្ខំឲ្យព្រះសង្ឃមួយចំនួនចេញពីវត្តមួយនៅក្នុងស្រុកមុខកំពូល ខេត្តកណ្តាល ហើយបង្ខំចិត្តលាចាកសិក្ខាបទដោយសារភ័យខ្លាចអាជ្ញាធរមូលដ្ឋានចាប់ផ្សឹក (“ពួកគេបានប្រើកាំភ្លើងបញ្ជាឲ្យពួកអាត្មាចេញពីវត្តៈ សង្ឃដីកា”) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) វិភាគអំពីសិទ្ធិសេរីភាពខាងសាសនា និងការគោរពសិទ្ធិនេះនៅកម្ពុជា ដោយរួមបញ្ចូលទាំងការសិក្សាពីបរិបទប្រវត្តិសាស្ត្រផងដែរ។ សេរីភាពខាងជំនឿគឺជាសិទ្ធិមនុស្សជាមូលដ្ឋាន។ នេះជាគោលការណ៍មួយដែលបុគ្គល ឬសហគមន៍អាចបង្រៀន អនុវត្ត គោរពបូជា ឬប្រតិបត្តិតាមជំនឿដែលគេជ្រើសរើស ក៏ដូចជាផ្លាស់ប្តូរជំនឿ ឬបដិសេធជំនឿដោយសេរី ទាំងនៅកន្លែងសាធារណៈ និងឯកជន។ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ច្បាប់ជាតិ និងច្បាប់អន្តរជាតិ

មាត្រា៤៣ នៃរដ្ឋធម្មនុញ្ញចែងពីសេរីភាពខាងជំនឿរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប – *“សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានាក្នុងលក្ខខណ្ឌ ដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសាធារណៈ”* ប៉ុន្តែ ស្របពេលជាមួយគ្នានេះ រដ្ឋធម្មនុញ្ញក៏ចែងផងដែរថាព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ សិទ្ធិសេរីភាពខាងជំនឿ ក៏ត្រូវបានធានាដោយច្បាប់អន្តរជាតិមួយចំនួនដែលកម្ពុជាបានផ្តល់សច្ចាប័នកាលពីឆ្នាំ១៩៩២ ដូចជាមាត្រា១៨ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា១៨ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ក្នុងឆ្នាំ១៩៨១ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីប្រកាសមួយស្តីពីការលុបបំបាត់រាល់ទម្រង់នៃការមិនយោគយល់អធ្យាស្រ័យ និងការរើសអើងខាងជំនឿសាសនា (“សេចក្តីប្រកាស”) ដែលផ្តល់អនុសាសន៍មួយចំនួនថាសិទ្ធិ និងសេរីភាពដែលមានជាធរមានត្រូវតែធានាដោយច្បាប់ជាតិដើម្បីឲ្យជនគ្រប់រូបអាចប្រើប្រាស់សិទ្ធិ និងសេរីភាពនោះក្នុងការអនុវត្តន៍ជាក់ស្តែង ហើយកម្ពុជាបានចែងគោលការណ៍នេះក្នុងរដ្ឋធម្មនុញ្ញ ប៉ុន្តែមិនបានចែងក្នុងច្បាប់ផ្សេងទៀតឡើយ (ប៉ុន្តែសេចក្តីប្រកាសនេះមិនមានកម្លាំងចាប់បង្ខំទេ)។

ការធ្វើទុក្ខបុកម្នេញលើជំនឿសាសនាដៅក្នុងរបបខ្មែរក្រហម (១៩៧-១៩៧៩)

ទោះបីជារដ្ឋធម្មនុញ្ញនៃ “កម្ពុជាប្រជាធិបតេយ្យ” (ដែលកម្ពុជាត្រូវបានគេស្គាល់ថាស្ថិតនៅក្រោមរបបខ្មែរក្រហម) ជាទ្រឹស្តីបានធានាសិទ្ធិខាងការគោរពសាសនា (ឬមិនគោរពប្រតិបត្តិសាសនា) អាស្រ័យទៅតាមជំនឿសាសនា ប៉ុន្តែនៅក្នុងការអនុវត្តន៍ជាក់ស្តែង អ្នកដឹកនាំបែរជាបានបំផ្លាញចោលជំនឿសាសនាទាំងស្រុង។ រាល់ “ប្រតិកិរិយាសាសនា” ត្រូវបានចាត់ទុកថាជាការប្រឆាំងនឹងឧត្តមគតិនៃរបបខ្មែរក្រហម ហើយត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹងបំផុត ក្នុងនោះមានព្រះសង្ឃពុទ្ធសាសនាជាច្រើនត្រូវបានគេចាប់ផ្សឹក ឬសម្លាប់ ហើយវត្តអារាម និងទីសក្ការៈបូជាដទៃទៀតជាច្រើនក៏ត្រូវបានបំផ្លាញចោល។ គ្រិស្តបរិស័ទ និងឥស្លាម បានប្រឈមនឹងការធ្វើទុក្ខបុកម្នេញយ៉ាងធ្ងន់ធ្ងរ ដូចជា ព្រះវិហារ៉ូម៉ាំងកាតូលិកនៅភ្នំពេញត្រូវបានបំផ្លាញចោលទាំងស្រុង ហើយអ្នកកាន់សាសនាឥស្លាមត្រូវបានគេបង្ខំឲ្យហូបសាច់ជ្រូកបើមិនអញ្ចឹងទេនឹងត្រូវធ្វើទារុណកម្មរហូតស្លាប់ (ពួកគេជាច្រើនបានជ្រើសយកជម្រើសទីពីរ)។ នៅក្នុងសំណុំរឿងលេខ ០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បកស្រាយយ៉ាងជាក់លាក់អំពីការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹង ក្រុមអ្នកកាន់សាសនាឥស្លាមដោយពួកខ្មែរក្រហម។ សហគមន៍បាហាអ៊ីកម្ពុជាស្ទើរតែត្រូវបានបាត់បង់ទាំងស្រុងក្នុងរបបខ្មែរក្រហម ដោយក្នុងនោះមានតែមនុស្សប៉ុន្មាននាក់ប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតក្រោយពីបាននិរទេសខ្លួនទៅក្នុងជំរុំភៀសខ្លួនក្នុងប្រទេសថៃ។

សេរីភាពខាងជំនឿនៅប្រទេសកម្ពុជាបច្ចុប្បន្ន

ចាប់តាំងពីឆ្នាំ១៩៧៩ កម្ពុជាបានបង្ហាញអំពីកម្រិតនៃការអធ្យាស្រ័យខាងជំនឿយ៉ាងធំធេងប៉ុន្តែនៅមានការរឹតត្បឹតមួយចំនួនតូច។ ឧទាហរណ៍ ក្រសួងធម្មការ និងសាសនាកាលពីឆ្នាំ២០០៣បានចេញសេចក្តីណែនាំមួយស្តីពីការគ្រប់គ្រងសាសានាមកពីក្រៅ ដែលតម្រូវឲ្យក្រុមសាសនាទាំងអស់ដាក់ពាក្យស្នើសុំមកក្រសួង មុននឹងសាងសង់ទីសក្ការៈបូជា ឬទីគោរពសកម្មភាពសាសនា។ ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ២០០៨ ក្រសួងបានចេញសេចក្តីណែនាំមួយដែលអនុញ្ញាតឲ្យសិស្សឥស្លាម និងបុគ្គលិកធ្វើការរដ្ឋដែលជាឥស្លាមទាំងអស់អាចស្លៀកសម្លៀកបំពាក់ឥស្លាមបានទាំងនៅក្នុងថ្នាក់ និងកន្លែងការងារ នេះគឺជាសញ្ញាណនៃការរីកចម្រើនមួយចំពោះសេរីភាពខាងសាសនា។ ទោះបីជាភាគច្រើនលើសលុបនៃប្រជាពលរដ្ឋកម្ពុជាគឺកាន់លទ្ធិពុទ្ធសាសនាថេរវាទ ប៉ុន្តែកម្ពុជាលើកតម្កើងភាពចម្រុះបែបនៃសាសនាភាគតិច៖

- ព្រះពុទ្ធសាសនា – តាមការប៉ាន់ស្មានមានប្រជាពលរដ្ឋកម្ពុជាប្រមាណជា ៩៦% គោរពពុទ្ធសាសនាថេរវាទ
- ឥស្លាម – ឥស្លាមគឺជាសាសនាដែលភាគច្រើននៃជនជាតិភាគតិចចាម និង ម៉ាឡេនៅកម្ពុជាគោរពបូជា ក្នុងនោះមានប្រជាពលរដ្ឋប្រហែលជា ២% គោរពប្រតិបត្តិសាសនាឥស្លាម ហើយភាគច្រើនលើសលុបគឺនៅសាលាស៊ុនី។
- គ្រិស្ត – តាមការប៉ាន់ស្មានមានប្រជាពលរដ្ឋកម្ពុជាប្រមាណជា ១,៣% គឺគ្រិស្តសាសនិកជន រួមមានប្រូតេស្តង់ កាតូលិក បាបទីស្ទ និងសាវកនៃព្រះវិហារយេស៊ូគ្រិស្តនៃថ្ងៃចុងក្រោយ។
- ហិនឌូ – ប្រជាពលរដ្ឋកម្ពុជាមួយចំនួននៅតែបន្តគោរពសាសនាដើមនៃចក្រភពខ្មែរបុរាណ។
- សាសនាផ្សេងៗទៀត – ជំនឿទំនៀមទម្លាប់ប្រជាប្រិយជនជាតិចិន ព្រះពុទ្ធសាសនាមហាយាន សាសនាតាវ និងលទ្ធិខុងជឺ គឺគោរពបូជាដោយប្រជាពលរដ្ឋកម្ពុជាមួយភាគតូច និងប្រជាជនអន្តោប្រវេសន៍ចិន និងវៀតណាមភាគច្រើន ខណៈដែលប្រជាពលរដ្ឋខ្មែរមួយចំនួនទៀតគោរពលើព្រលឹងអារ័ក្សអ្នកតាតាមបែបជនជាតិដើមភាគតិច – ហើយដែលជារឿយៗគឺលាយជាមួយនឹងសាសនាព្រះពុទ្ធ។

ការរឹតត្បឹតសេរីភាពខាងសាសនាដោយផ្អែកលើមូលដ្ឋានយោបាយ

រាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) បានរឹតត្បឹតសិទ្ធិព្រះសង្ឃពុទ្ធសាសនាក្នុងការប្រតិបត្តិ សូម្បីតែការរឹតត្បឹតនោះផ្អែកលើមូលដ្ឋាននយោបាយជាជាងមូលដ្ឋានសាសនាក៏ដោយ។ ករណីមួយជាប់ទាក់ទងនឹងព្រះតេជគុណ លួន សាវ៉ាត ដែលបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយចម្រុះបែប និងដែលត្រូវបានគេហាមឃាត់មិនឲ្យនិមន្តចូលវត្តរបស់ព្រះអង្គ និងវត្តដទៃទៀតនៅទីក្រុងភ្នំពេញ ហើយព្រះអង្គទទួលរងការគម្រាមរាប់មិនអស់ពីសំណាក់គណៈសង្ឃដែលគាំទ្ររដ្ឋាភិបាល ដោយសារព្រះអង្គទាមទារសិទ្ធិឲ្យជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ ករណីមួយទៀតគឺជាប់ទាក់ទិននឹងព្រះសង្ឃកម្ពុជាក្រោម ព្រះនាម ទឹម សាខន ដែលត្រូវបានចាប់ខ្លួន និងផ្សឹកដោយអាជ្ញាធរកម្ពុជាកាលពីឆ្នាំ២០០៧ ហើយត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ ដោយខុសច្បាប់ជាតិ និងអន្តរជាតិ និងសិទ្ធិមិនត្រូវបានគេនិរទេសខ្លួនចេញពីប្រទេសដែលខ្លួនមានសញ្ជាតិ។ ព្រះតេជគុណ ទឹម សាខន បានលើកកម្ពស់សិទ្ធិខ្មែរក្រោមយ៉ាងសកម្ម ហើយត្រូវបានគេចាប់ផ្សឹកពីបទចោទប្រកាន់ព្រះអង្គថាបានធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងកម្ពុជា វៀតណាម មុនពេលត្រូវបានគេកាត់ទោសឲ្យជាប់ពន្ធនាគារមួយឆ្នាំនៅប្រទេសវៀតណាមពីបទបង្កអន្តរាយដល់គោលនយោបាយឯកភាពជាតិ។ មូលហេតុនៃការបណ្តេញចេញពីវត្តនាពេលថ្មីៗនេះ ដែលបានលើកឡើងក្នុងសេចក្តីផ្តើមគេនៅមិនទាន់ដឹងនៅឡើយទេ។

សេចក្តីសន្និដ្ឋាន

សេរីភាពខាងសាសនា គឺជាសិទ្ធិជាមូលដ្ឋានសម្រាប់មនុស្សគ្រប់រូបក្នុងសង្គម ហើយការលើកទឹកចិត្តឲ្យមានភាពចម្រុះបែប – មិនថាតែសាសនា ឬអ្វីផ្សេងទៀត – គឺជាសូចនាករចង្អុលបង្ហាញអំពីសង្គមដែលរីកចម្រើនមួយ។ កម្ពុជាប្រព្រឹត្តបានល្អចំពោះសេរីភាពជាមូលដ្ឋានមួយនេះ ជាពិសេសបើប្រៀបធៀបទៅនឹងការគាបសង្កត់ដែលបានកើតឡើងកាលពីអតីតកាលនាពេលថ្មីៗនេះ។ តាមការពិត រដ្ឋាភិបាលគួរតែធ្វើឲ្យកាន់តែល្អប្រសើរដើម្បីឆ្លុះបញ្ចាំងអំពីការគោរពភាពចម្រុះបែប លើកកម្ពស់ការយោគយល់អធ្យាស្រ័យ និងទប់ស្កាត់ការរើសអើង ដូចអ្វីដែលកម្ពុជាបានធ្វើក្នុងវិស័យសាសនាក្នុងការពង្រីកទង្វើល្អនេះទៅក្នុងសេរីភាពជាមូលដ្ឋាន និងក្រុមភាគតិចដទៃទៀត ដែលនៅក្រោមការគំរាមកំហែងដ៏ធ្ងន់ធ្ងរនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។ ទោះជាយ៉ាងណាក៏ដោយសិទ្ធិសេរីភាពខាងជំនឿគឺត្រូវតែមានលក្ខណៈដាច់ខាត ហើយមិន គួរត្រូវបានរឹតត្បឹតដោយរដ្ឋាភិបាលឡើយ មិនថាក្នុងកាលៈទេសៈណាក៏ដោយ រួមមានដូចជាការរឹតត្បឹតនោះកើតចេញពីការរឹតត្បឹតសិទ្ធិពលរដ្ឋ ឬសិទ្ធិនយោបាយជាជាងសិទ្ធិខាងជំនឿសាសនាជាដើម។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង លោក អ៊ូ វីរៈ តាមរយៈទូរស័ព្ទលេខ (៨៥៥) ១២ ៤០ ៤០ ៥១ ឬតាមរយៈអ៊ីមែល ouvirak@cchrcambodia.org **ឬលោក រ៉ូប៊ឺត ហ្វីន តាមរយៈទូរស័ព្ទលេខ (៨៥៥) ៧៨ ៨០ ៩៩ ៦០ ឬតាមរយៈអ៊ីមែល** robert.finch@cchrcambodia.org ។